# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Sep-2014, 15:50
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## មតិតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន
## ចំពោះសំណើពីរដំបូងរបស់មេធាវីការពារក្ដីលោក នួន ជា សុំឱ្យទទួល
## និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខ

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
| --- | --- |
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះតុលាការកំពូល៖** |
| មេធាវី គង់ សំអុន | ចៅក្រម គង់ ស្រីម |
| មេធាវី Anta GUISSÉ | ចៅក្រម Agnieszka KLONOWIECKA-MILART |
| មេធាវី Arthur VERCKEN | ចៅក្រម សោម សិរីវឌ្ឍ |

ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Soumeya MEDJEBEUR
លោក Pierre TOUCHE
កញ្ញា អ៊ូច ស្រីផាត់
កញ្ញា Cécile ROUBEIX
លោក Clément BOSSIS

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្ដីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ ហើយបានប្រកាសថាលោក ខៀវ សំផន និងលោក នួន ជា មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងបានផ្តន្ទាទោសលោក ខៀវ សំផន និងលោក នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត[1]។

២. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីលោក ខៀវ សំផន និងមេធាវីការពារក្តីលោក នួន ជា បានស្នើសុំពន្យារពេលកំណត់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ព្រមទាំងបានស្នើសុំបង្កើនចំនួនទំព័រនៃឯកសារទាំងពីរនេះ[2]។

៣. ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានឯកភាពលើចំណុចខ្លះនៃសំណើរបស់មេធាវីការពារក្តីទាំងពីរក្រុម ដោយអនុញ្ញាតឲ្យដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ក្នុង រយៈពេល ៣០ ថ្ងៃ ចាប់ពីពេលខ្លួនចេញសេចក្តីសម្រេចនេះ[3] គឺត្រឹមថ្ងៃទី ២៩ កញ្ញា ឆ្នាំ ២០១៤។

៤. ក្នុងក្របខ័ណ្ឌនៃបណ្តឹងសាទុក្ខ នៅថ្ងៃទី ០១ និងថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីលោក នួន ជា បានដាក់សំណើពីរ សុំឲ្យទទួល និងពិចារណាទៅលើភ័ស្តុតាងបន្ថែម។ តាមរយៈសារណានេះ មេធាវីការពារក្តីលោក ខៀវ សំផន (មេធាវីការពារក្តី) សូមគាំទ្រយ៉ាងពេញទំហឹងចំពោះសំណើទាំងពីរនេះ[4]។

---

[1] សាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E313** ("សាលក្រម")។

[2] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន និងមេធាវីការពារក្តីលោក នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **F3**។

[3] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **F3/3**។

[4] លើកលែងតែយល់ច្បាស់ទាំងស្រុង នៅពេលទទួលបានសំណៅបកប្រែនៃសំណើទាំងពីរនេះជាភាសាបារាំង ដែលបានស្នើសុំបកប្រែជាបន្ទាន់។

៥. សំណើទីមួយ ដែលមានចំណងជើងថា *"សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទង នឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១"*[5] (សំណើទីមួយ) គឺជាសំណើសុំដាក់ជាភស្តុតាងនូវកិច្ចសម្ភាសន៍រវាង ថេត សម្បត្តិ ជាមួយនឹងវិទ្យុសម្លេងសហរដ្ឋអាមេរិក (វីអូអេ) ជាភាសាខ្មែរ នៅថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ និងជាសំណើសុំកោះហៅ ថេត សម្បត្តិ និង Rob LEMKIN ជាសហ-សមិទ្ធករ និងសហផលិតករនៃខ្សែភាពយន្តចំនួនពីរ ដែលនិយាយពាក់ព័ន្ធនឹងអង្គហេតុជាកម្មវត្ថុនៃសំណុំរឿង ០០២/០១។

៦. មេធាវីការពារក្តីសូមទទួលយកទាំងស្រុងនូវទឡ្ហីករណ៍របស់មេធាវីការពារក្តីលោក នួន ជា ដែលបានលើកឡើង នៅក្នុងសំណើទីមួយ។ មេធាវីការពារក្តីសូមរំឭកថា ខ្លួនក៏ធ្លាប់បានគាំទ្រផងដែរទៅលើសំណើសុំកោះហៅ Rob LEMKIN ឱ្យមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣[6]។ ច្បាស់ណាស់ថា ភស្តុតាងទាំងនេះមានទំនាក់ទំនងដោយផ្ទាល់ជាមួយអង្គហេតុ ដែលលោក ខៀវ សំផន ត្រូវបានផ្តន្ទាទោសដោយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ ដូច្នេះ ភស្តុតាងទាំងនេះមានសារៈសំខាន់បំផុត ក្នុងក្របខ័ណ្ឌនៃបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមនេះ។

៧. នៅក្នុងសំណើទីពីរដែលមានចំណងជើងថា *"សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង*

[5] សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **F2**។

[6] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E1/223.1** ទំព័រ ៧៦-៧៧ (ចន្លោះពីម៉ោង [15.29.47] ដល់ម៉ោង [15.32.40])។

*០០២/០១*”[7] (សំណើទីពីរ) មេធាវីការពារក្ដីលោក នួន ជា បានស្នើសុំដាក់ជាភ័ស្ដុតាងនូវវីដេអូនៃបទសម្ភាសន៍របស់លោកស្រីចៅក្រម Silvia CARTWRIGHT នៅវិទ្យាស្ថាន Aspen និងសម្រង់ចេញពីសៀវភៅរបស់លោក Marcel LEMONDE អតីតសហចៅក្រមស៊ើបអង្កេតអន្ដរជាតិ។ មេធាវីការពារក្ដីសូមគាំទ្រទាំងស្រុងទៅលើទឡ្ហីករណ៍របស់មេធាវីការពារក្ដីលោក នួន ជា ដែលបានលើកឡើងនៅក្នុងសំណើទីពីរនេះ។

៨. មេធាវីការពារក្ដីសូមគូសបញ្ជាក់ថា វីដេអូរបស់លោកស្រីចៅក្រម Silvia CARTWRIGHT មាននៅក្នុងបញ្ជីភ័ស្ដុតាង ដែលខ្លួនចង់ប្រើប្រាស់ នៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២។ ខ្លឹមសារនៃសម្ដីរបស់លោកស្រីចៅក្រម លើកឡើងនូវបញ្ហាធ្ងន់ធ្ងរ និងជាមូលដ្ឋានពាក់ព័ន្ធនឹងភាពលម្អៀងរបស់ក្រុមប្រឹក្សាជំនុំជម្រះ ដែលបានផ្ដន្ទាទោសលោក ខៀវ សំផន និងប៉ះពាល់ដល់វិធាននៃការជំនុំជម្រះក្ដីប្រកបដោយភាពយុត្តិធម៌ ជាអាទិ៍ គឺសច្ចធារណ៍និរទោស។ បញ្ហាទាំងនេះបន្ថែមទៅលើកង្វល់របស់មេធាវីការពារក្ដី ដូចបានរៀបរាប់នៅក្នុងសំណើសុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្ដើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤[8]។

៩.ម្យ៉ាងវិញទៀត មេធាវីការពារក្ដីនៅតែរក្សាគោលជំហរដដែល ចំពោះសំណើសុំឱ្យទទួលយកជាភ័ស្ដុតាងនូវសម្រង់ចេញពីសៀវភៅរបស់លោក Marcel LEMONDE។ ជាក់ស្ដែង

---

[7] សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភ័ស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **F2/1**។

[8] សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្ដើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E314/1**។

ដូចមេធាវីការពារក្តីលោក នួន ជា បានរំឭកនៅក្នុងសំណើទីពីររបស់ខ្លួន[9] ការស្នើសុំដាក់ជាភស្តុតាងនូវសម្រង់ចេញពីសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត ធ្លាប់ជាកម្មវត្ថុនៃសំណើពីររបស់មេធាវីការពារក្តី កាលពីខែ មេសា និងខែ ឧសភា ឆ្នាំ ២០១៣[10]។ ដូច្នេះ យើងខ្ញុំត្រូវតែគូសបញ្ជាក់ថា សេចក្តីសម្រេចបដិសេធសំណើនេះដោយអង្គជំនុំជម្រះសាលាដំបូង[11] ស្ថិតនៅក្នុងចំណោម សេចក្តីសម្រេចនានា ដែលមេធាវីការពារក្តីមានបំណងប្តឹងសាទុក្ខ ក្នុងពេលដំណាលគ្នានឹងការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។

១០. ក៏ដូចជាមេធាវីការពារក្តីលោក នួន ជា ផងដែរ មេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា ព័ត៌មាននៅក្នុងសៀវភៅនេះ ចោទជាបញ្ហាចំពោះភាពលម្អៀង និងឯករាជ្យភាពរបស់ អ.វ.ត.ក ហើយផ្តល់ជាប្រទីបបំភ្លឺអំពីល័ក្ខខ័ណ្ឌ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ប្រទីបដែលចោទជាបញ្ហាលើការធានាអំពីការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌។ ដូច្នេះ ព័ត៌មានទាំងនេះក៏មានសារៈសំខាន់បំផុតផងដែរ នៅក្នុងការពិភាក្សារបស់មេធាវីការពារក្តីលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដែលនាំទៅដល់ការផ្តន្ទាទោសលោក ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

## អាស្រ័យហេតុនេះ

១១. មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

- **ប្រកាស** ថាមេធាវីការពារក្តីលោកខៀវ សំផន

---

[9] សំណើទីពីរ ឯកសារ **F2/1** កថាខណ្ឌ ៥។

[10] សំណើលើកទី១ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E280**, សំណើលើកទី២ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E280/2**។

[11] សេចក្តីសម្រេចលើសំណើសុំលើកទីពីររបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកអត្ថបទដកស្រង់ចេញពីសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត Marcel LEMONDE (ឯកសារ E280/2) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E280/2/1**។

គាំទ្រទាំងស្រុងចំពោះសំណើពីរដំបូងរបស់មេធាវីការពារក្ដីលោក នួន ជា សុំឱ្យទទួល និងពិចារណាទៅលើភ័ស្ដុតាងបន្ថែម (ឯកសា F2 និង F2/1)។

ហេតុដូចនេះ

- **ទទួលយក** និង **ពិចារណា** ទៅលើកិច្ចសម្ភាសន៍រវាង ថេត សម្បត្តិ ជាមួយនឹងវីអូអេ ជាភាសាខ្មែរ នៅថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ដែលមានលេខ ERN T01022159 និង T01022160។
- **បង្គាប់ឲ្យកោះហៅ** ថេត សម្បត្តិ និង Rob LEMKIN ដើម្បីសួរដេញដោលទៅលើភ័ស្ដុតាងដែលបានលើកឡើងនៅក្នុងកិច្ចសម្ភាសន៍នេះ។
- **ទទួលយក** និង **ពិចារណា** ទៅលើវីដេអូនៃបទសម្ភាសន៍លោកស្រីថៅក្រម CARTWRIGHT នៅវិទ្យាស្ថាន Aspen នៅខែ វិច្ឆិកា ឆ្នាំ ២០១៣ ដែលមានលេខយោង E305/12.38R។
- **ទទួលយក** និង **ពិចារណា** ទៅលើសម្រង់ចេញពីសៀវភៅរបស់លោក Marcel LEMONDEដែលមានលេខ E189/3/1/7.1.1, E189/3/1/7.1.2, E189/3/1/7.1.3 និង E189/3/1/7.1.4។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |